លេខសំណុំរឿង:_____

កម្មវិធីសេវាការមើលថែទាំក្នុងផ្ទះ (IHSS) សេចក្តីថ្លែងការណ៍របស់អ្នកទទួលជំនួយអំពីសេចក្តីតម្រូវលើ សប្តាហ៍ធ្វើការ និង ការធ្វើការលើសម៉ោង

ឯកសារនេះផ្តល់ព័ត៌មានអំពីសេចក្តីតម្រូវលើសប្តាហ៍ធ្វើការ និងការធ្វើការលើសម៉ោង ដែលត្រូវបានអាណត្តិទៅតាមច្បាប់រដ្ឋ (ច្បាប់វ៉ែលហ្វ៉ែរនិងស្ថាប័ន វគ្គលេខ 12300.4 និង 12301.1) សម្រាប់កម្មវិធី IHSS ។ ខ្ញុំត្រូវតែអានព័ត៌មាន ហើយនឹងចុះហត្ថលេខានៅលើសំណៅនេះ ដើម្បីបង្ហាញថាខ្ញុំយល់ និងយល់ព្រមធ្វើតាមសេចក្តីតម្រូវទាំងអស់នេះ។

- ក្រោមច្បាប់រដ្ឋ, ចំនួនម៉ោងច្រើនបំផុតដែលអ្នកផ្តល់សេវា IHSS អាចធ្វើការក្នុងមួយសប្តាហ៍ធ្វើការ ដោយការផ្តល់សេវាដែលបានអនុញ្ញាត គឺ ចំនួនម៉ោងជាអតិបរិមាប្រចាំសប្តាហ៍។ ចំនួនម៉ោងអនុញ្ញាតប្រចាំខែ ទាំងអស់របស់ខ្ញុំ នៅពេលនេះ នឹងត្រូវបានចែកនឹង 4 ដើម្បីកំណត់នូវចំនួនម៉ោងជាអតិបរិមាប្រចាំសប្តាហ៍របស់ខ្ញុំ។ សប្តាហ៍ធ្វើការ ចាប់ផ្តើមនៅម៉ោង 12:00 a.m. (ពាក់កណ្តាលយប់) នៅថ្ងៃអាទិត្យ និងចប់នៅម៉ោង 11:59 p.m. នៅថ្ងៃសៅរ៍បន្ទាប់។

- ខ្ញុំអាចអនុញ្ញាតឲ្យអ្នកផ្តល់សេវារបស់ខ្ញុំ លៃតម្រូវគម្រោងពេលម៉ោងធ្វើការរបស់គាត់/នាង ដើម្បីធ្វើការច្រើនជាងម៉ោងធ្វើការធម្មតារបស់គាត់/នាង នៅអំឡុងពេលសប្តាហ៍ធ្វើការ <u>ដោយមិនបាច់ស្នើសុំខោនធីសម្រាប់ការយល់ព្រមនោះទេ</u> ដរាបណាដែល វាមិនបណ្តាលឲ្យអ្នកផ្តល់សេវារបស់ខ្ញុំ:

  1. ធ្វើការបន្ថែមម៉ោងនៅក្នុងខែ ច្រើនជាងចំនួនម៉ោង ដែលគាត់/នាងតែងតែធ្វើការជាធម្មតា;

  2. ធ្វើការច្រើនជាង 40 ម៉ោងក្នុងមួយសប្តាហ៍ធ្វើការ បើសិនជា ចំនួនម៉ោងជាអតិបរិមាប្រចាំសប្តាហ៍ គឺ 40 ម៉ោង ឬតិចជាងក្នុងមួយសប្តាហ៍ធ្វើការ; និង

  3. ធ្វើការច្រើនជាង 66 ម៉ោងក្នុងមួយសប្តាហ៍ធ្វើការ បើសិនជា អ្នកផ្តល់សេវារបស់ខ្ញុំធ្វើការឲ្យអ្នកទទួលជំនួយច្រើននាក់។

- រាល់ពេលដែលអ្នកផ្តល់សេវារបស់ខ្ញុំធ្វើកិច្ចការណាមួយខាងក្រោមនេះ, គាត់/នាង នឹងត្រូវបានទទួលការរំលោភលើច្បាប់មួយ:

  1. អ្នកផ្តល់សេវារបស់ខ្ញុំ មានតែខ្ញុំម្នាក់ជាអ្នកទទួលជំនួយ ហើយ គាត់ធ្វើការឲ្យខ្ញុំច្រើនជាង 40 ម៉ោងក្នុងមួយសប្តាហ៍ធ្វើការ ដោយមិនបានទទួលការយល់ព្រមពីខោនធីទេ នៅពេលដែល ចំនួនម៉ោងជាអតិបរិមាប្រចាំសប្តាហ៍របស់ខ្ញុំ គឺមាន 40 ម៉ោង ឬតិចជាង ក្នុងមួយសប្តាហ៍ធ្វើការ;

  2. អ្នកផ្តល់សេវារបស់ខ្ញុំ មានអ្នកទទួលជំនួយច្រើនជាងម្នាក់, ហើយ គាត់/នាងធ្វើការច្រើនជាង 66 ម៉ោងក្នុងមួយសប្តាហ៍ធ្វើការ;

លេខសំណុំរឿង:_____

3. អ្នកផ្តល់សេវាធ្វើការឲ្យខ្ញុំច្រើនជាងចំនួនម៉ោងជាអតិបរិមាប្រចាំសប្តាហ៍របស់ខ្ញុំ ក្នុងមួយសប្តាហ៍ធ្វើការ ដោយមិនបានទទួលការយល់ព្រមពីខោនធីនោះទេ, ដែលជាហេតុបណ្តាលឲ្យលើសម៉ោងបន្ថែមទៀតនៅក្នុងខែ ច្រើនជាងម៉ោងធ្វើការធម្មតា; ឬ

4. ការទាមទារម៉ោងធ្វើដំណើររបស់អ្នកផ្តល់សេវារបស់ខ្ញុំ គឺច្រើនជាងប្រាំពីរម៉ោង ក្នុងមួយសប្តាហ៍ធ្វើការ។

- ជួនកាល ខ្ញុំប្រហែលជាត្រូវការឲ្យអ្នកផ្តល់សេវាធ្វើការឲ្យខ្ញុំ ច្រើនជាងចំនួនម៉ោងជាអតិបរិមាប្រចាំសប្តាហ៍របស់ខ្ញុំ។ ខ្ញុំត្រូវតែស្នើសុំទៅខោនធីសម្រាប់ការយល់ព្រមក្នុងការលៃតម្រូវចំនួនម៉ោងជាអតិបរិមាប្រចាំសប្តាហ៍របស់ខ្ញុំ; ទោះបីជាខោនធីយល់ព្រមលើការស្នើសុំសម្រាប់ការលើកលែងនេះ ក៏ដោយ, ខ្ញុំនឹងត្រូវតែឲ្យអ្នកផ្តល់សេវារបស់ខ្ញុំ ធ្វើការតិចម៉ោង នៅក្នុងសប្តាហ៍បន្ទាប់នៃខែ ដូច្នេះហើយ ខ្ញុំមិនបានលើសចំនួនម៉ោងដែលបានអនុញ្ញាតប្រចាំខែរបស់ខ្ញុំ នោះទេ។ ខោនធីនឹងផ្ញើសេចក្តីជូនដំណឹងមួយច្បាប់ ដើម្បីប្រាប់ខ្ញុំឲ្យដឹងថាតើ ការស្នើសុំសម្រាប់ការលើកលែងរបស់ខ្ញុំ ត្រូវបានយល់ព្រម ឬត្រូវបានបដិសេធ។

- ខោនធីនឹងផ្ញើមកឲ្យខ្ញុំនូវសេចក្តីជូនដំណឹងមួយច្បាប់ នៅពេលដែលអ្នកផ្តល់សេវារបស់ខ្ញុំទទួលបានការរំលោភលើច្បាប់មួយ។ បើសិនជាអ្នកផ្តល់សេវារបស់ខ្ញុំ ទទួលបានការរំលោភលើច្បាប់ ចំនួនបីដង, គាត់/នាងនឹងត្រូវបានបញ្ឈប់បណ្តោះអាសន្នពីការផ្តល់សេវា IHSS ក្នុងរយៈពេលបីខែ។ បើគាត់/នាង ទទួលបានការរំលោភលើច្បាប់មួយផ្សេងទៀត ក្រោយពីត្រូវបានចាត់តាំងឲ្យធ្វើជាអ្នកផ្តល់សេវា ដោយការបញ្ឈប់បណ្តោះអាសន្នក្នុងរយៈពេលបីខែ, គាត់/នាង នឹងត្រូវគេបញ្ឈប់ពីកិច្ចការជាអ្នកផ្តល់សេវា ក្នុងរយៈពេលមួយឆ្នាំ។

ការទទួលស្គាល់របស់អ្នកទទួលជំនួយ

ខ្ញុំយល់ និងយល់ព្រមធ្វើតាមសេចក្តីតម្រូវទាំងអស់ ដែលបានចុះនៅក្នុងសំណុំបែបបទនេះ។

ហត្ថលេខារបស់អ្នកទទួលជំនួយ:	ខែថ្ងៃឆ្នាំ:
ឈ្មោះអ្នកទទួលជំនួយសរសេរជាអក្សរពុម្ព:	
ហត្ថលេខារបស់អ្នកតំណាងពេញច្បាប់:	ខែថ្ងៃឆ្នាំ:
ឈ្មោះអ្នកតំណាងពេញច្បាប់សរសេរជាអក្សរពុម្ព:	

សម្រាប់តែខោនធីប្រើប៉ុណ្ណោះ

WORKER NAME:	DATE: